**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ ៖ ១៣៧៥.................ក.ប/ប្រ.ក**

# ប្រកាស

## ស្តីពី

## ការតម្លើងកម្រិតបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- លិខិតលេខ ០១៩/១១ មបវ.ខសន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១ របស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ

## សម្រេច

**ប្រការ ១ ៖** អនុញ្ញាតឱ្យតម្លើងកម្រិតបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ ពីថ្នាក់វិញ្ញាបនបត្រទៅថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត១ កម្រិត២ កម្រិត៣ ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង ។

**ប្រការ ២ ៖** មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ មានភារកិច្ចធ្វើការបណ្តុះបណ្តាល ៖

- ថ្នាក់វិញ្ញាបនបត្រ បណ្តុះបណ្តាលរយៈពេលក្រោម១ឆ្នាំទៅតាមជំនាញវិជ្ជាជីវៈ
- ថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ សិក្សារយៈពេល ១ឆ្នាំ ឬ២ឆ្នាំ ឬ៣ឆ្នាំ(៩+១+១+១)
- ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ ត្រូវនឹង៨០ក្រេឌីត

**ប្រការ ៣ ៖** ចំពោះមុខមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

១- ការិយាល័យរដ្ឋបាល និងបុគ្គលិក

២- ការិយាល័យហិរញ្ញវត្ថុ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ:(០២៣)៨៨ ២៧ ០៩

៣- ការិយាល័យសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

៤- ការិយាល័យផែនការ និងទំនាក់ទំនងទីផ្សារ

នៅថ្ងៃអនាគតមជ្ឈមណ្ឌលនេះអាចបើកការិយាល័យ ដេប៉ាតឺម៉ង់ ឬជំនាញផ្សេងទៀត ដោយសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ប្រការ ៤ :** លក្ខខណ្ឌទទួលសិស្ស-និស្សិតឲ្យចូលរៀន ៖

ក- ថ្នាក់វិញ្ញាបនបត្រ បេក្ខជនជាសិក្ខាកាម សិស្ស-និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ ។

ខ- ថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ បេក្ខជនបានរៀនចប់ថ្នាក់ទី៩ នៃមធ្យមសិក្សាបឋមភូមិ ឬវិញ្ញាបនបត្រកម្មវិធីស្ពានចម្លងបន្តជំនាញ ។

គ- ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង បេក្ខជនទាំងពីរភេទត្រូវមានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ឬបានប្រឡងជាប់ ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ ។

មជ្ឈមណ្ឌលត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើសសិស្ស-និស្សិតឲ្យចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

**ប្រការ ៥ :** មជ្ឈមណ្ឌលនេះមានឋានៈស្មើនឹងការិយាល័យនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ។

**ប្រការ ៦ :** នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ មានបុព្វសិទ្ធិស្មើនឹងប្រធានការិយាល័យនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត និងមាននាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ។ មជ្ឈមណ្ឌលត្រូវធ្វើរបាយការណ៍រាល់សកម្មភាពសិក្សាជូននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឲ្យបានទៀងទាត់តាមការកំណត់ ។

**ប្រការ ៧ :** សិស្ស-និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់មជ្ឈមណ្ឌលនេះ នឹងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សាត្រូវទទួលបានតាមកម្រិត និងតាមឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះផ្តល់ឲ្យដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ និងត្រូវបានទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីមជ្ឈមណ្ឌលនេះបានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ប្រការ ៨ :** នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ មានភារកិច្ចរៀងៗខ្លួនប្រតិបត្តិតាមប្រកាសនេះ ។

**ប្រការ ៩ :** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១

រដ្ឋមន្ត្រី

វង សុត

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម និងលោកជំទាវឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាក់ព័ន្ធ
- សាលាខេត្តព្រះសីហនុ
  " ដើម្បីជូនជ្រាប "
- គ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  " ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារៈ(០២៣)៨៨ ២៧ ៦៩